ភ្នំពេញ, ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មានស្តីពី៖ ការអញ្ជើញចូលរួមក្នុងវេទិកាយុវជន

គណៈកម្មាធិការដើម្បីការបោះឆ្នោតដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា (ខុមហ្វ្រែល) បានបង្កើត គេហទំព័រ«សម្លេងម្ចាស់ឆ្នោត(Tracking MPs) ដែលផ្តល់ឱកាសឲ្យប្រជាពលរដ្ឋម្ចាស់ឆ្នោត មានលទ្ធភាពតាមដានសកម្មភាព ការផ្តល់មតិយោបល់ ការវាយតម្លៃដោយផ្តល់ពិន្ទុ និងលើកជាសំណួរទៅកាន់តំណាងរាស្រ្ត ។

អាស្រ័យដូចបានជំរាបជូនខាងលើ ខុមហ្វ្រែល មានកិត្តិយសអញ្ជើញយុវជនចំនួន១២០នាក់ ដែលជាសិស្ស និស្សិត និងតំណាង ឬបណ្តាញអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ចូលរួមក្នុងវេទិកាយុវជនស្តីពី «**ការប្រើប្រាស់កម្មវិធីសម្លេងម្ចាស់ឆ្នោត** ( Tracking MPs )»។

- កាលបរិច្ឆេទ ៖ ថ្ងៃអាទិត្យ ទី២០ ខែកញ្ញា ឆ្នាំ២០១៥
- ពេលវេលា ៖ ម៉ោង ៧:៣០- ១០:០០ ព្រឹក
- ទីកន្លែង ៖ ស្នាក់ការអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
  (ផ្ទះលេខ៩៣ ផ្លូវលេខ៥៩០ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ)

## លក្ខខ័ណ្ឌអ្នកចូលរួម៖

- មាន Smart Phone ឬ Laptop
- ក្រោយបញ្ចប់វេទិកា ស្ម័គ្រចិត្តស្វែងរកអ្នកប្រើប្រាស់វេទិកាសម្លេងម្ចាស់ឆ្នោត (Tracking MPs)
- មានឆន្ទៈផ្សព្វផ្សាយបន្តអំពីវេទិកាសម្លេងម្ចាស់ឆ្នោត (Tracking MPs)

## ចុះឈ្មោះចូលរួម ឬសួរព័ត៌មានបន្ថែមរៀងរាល់ម៉ោងធ្វើការតាមរយៈ

ទូរស័ព្ទលេខ៖ ០១០ ៥៣ ៥៣ ៥៤

អ៊ីម៉ែល៖ sreypich@comfrel.org

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យ។

**Vision** : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**<u>បេសកកម្ម</u>** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្រ្តីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្រ្តីជាប់ឆ្នោត។

<u>ទីស្នាក់ការកណ្តាល</u> ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**<u>Central Office</u> : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**
**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org